# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅ
## នៃគណៈកម្មការសុរិយោដី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី
ចូល លេខ 2224
ចុះថ្ងៃទី 5-6-2002
បញ្ជូន

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៤៧...អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ/បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

-បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០២

# សំ រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### មាត្រា ១ ..

អនុក្រឹត្យនេះ មានគោលដៅកំណត់រចនាសម្ព័ន្ធ បេសកកម្ម និង មុខងារ របស់គណៈកម្មការសុរិយោដី។

### មាត្រា ២ ..

អនុក្រឹត្យនេះអនុវត្តចំពោះវិវាទ ដែលទាក់ទងនឹងអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីសុរិយោដី។ ក្នុងករណីនេះ គណៈកម្មការសុរិយោដីមានសិទ្ធិសំរេចមុនគេក្នុងការទទួលស្គាល់ភោគីស្របច្បាប់។

## ជំពូកទី ២
## រចនាសម្ព័ន្ធ និង បេសកកម្ម

### មាត្រា ៣ ..

គណៈកម្មការសុរិយោដី ត្រូវមានបេសកកម្មដោះស្រាយវិវាទទាក់ទងនឹងអចលនវត្ថុ ដែលមិនទាន់បានចុះបញ្ជីសុរិយោដី ដូចតទៅ :

១.-វិវាទដែលកើតមាននៅក្រៅតំបន់វិនិច្ឆ័យ

២.-វិវាទ ដែលកើតមាននៅក្នុងតំបន់វិនិច្ឆ័យ និងដែលមិនអាចសម្រុះសម្រួលបានដោយគណៈកម្មការរដ្ឋបាល។

### មាត្រា ៤ ..

គណៈកម្មការសុរិយោដី មានរចនាសម្ព័ន្ធដូចតទៅ :

១.-គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានអក្សរកាត់ថា គ.ស.ស.ខ មានទីតាំងនៅក្នុងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ។

២.-គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានអក្សរកាត់ថា គ.ស.ខ.ក មានទីតាំងនៅក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ។

៣.-គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានអក្សរកាត់ថា គ.ស.ជ មានទីតាំងនៅក្នុងទីស្តីការក្រសួង

រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងគណៈកម្មការសុរិយោដីថ្នាក់ជាតិ មានលេខាធិការដ្ឋាន ជាសេនាធិការ និងជាអង្គភាពស៊ើបអង្កេត។

## ជំពូកទី ៣
## គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ

**មាត្រា ៥ ..**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដឹកនាំដោយប្រធានមួយរូបដែលជាប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ហើយត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានមន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ជាសមាជិក។

ប្រធានគណៈកម្មការនេះ ត្រូវអញ្ជើញតំណាងអាជ្ញាធរដែនដីស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ ដែលពាក់ព័ន្ធ ឬ/និង ចាស់ព្រឹទ្ធាចារ្យនៅក្នុងមូលដ្ឋានឱ្យចូលរួមជាសមាជិកអាដហុក។

**មាត្រា ៦ ..**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានភារកិច្ចសម្រុះសម្រួលវិវាទ ដែលកើតមានឡើងនៅក្រៅតំបន់វិនិច្ឆ័យ។ ការសម្រុះសម្រួលវិវាទ ត្រូវអនុវត្តតាមទម្លាប់ប្រពៃណី និងបច្ចេកទេសសុរិយោដី។

## ជំពូកទី ៤
## ការសម្រុះសម្រួលនៅថ្នាក់ស្រុក ខណ្ឌ

**មាត្រា ៧ ..**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ទំរង់បែបបទនៃពាក្យបណ្តឹង។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវចុះបញ្ជី និងបើកសំណុំរឿងនៃវិវាទដែលបានទទួល។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវពន្យល់អំពីនីតិវិធីដល់ភាគីវិវាទ និងសាកសួរថាតើគូវិវាទយល់ព្រមធ្វើការដោះស្រាយសម្រុះសម្រួលតាមនីតិវិធីនេះឬទេ ។

មាត្រា ៨ ..

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវស៊ើបអង្កេតលើវិវាទ ។ ការស៊ើបអង្កេតរួមមាន ការបញ្ជាក់អំពីទីតាំងនៃក្បាលដី ដែលមានវិវាទ និងភាគីពាក់ព័ន្ធ និងអំពីកម្មវត្ថុនៃវិវាទ និងការប្រមូលឯកសារ ដែលមានចម្លើយរបស់សាក្សី និងពត៌មានទាក់ទងនឹងក្បាលដីមានវិវាទ ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវថតចម្លង និងបញ្ជាក់លើឯកសារចម្លងនោះ សំរាប់ទុកជាសំណុំរឿង និងប្រគល់ច្បាប់ដើមឱ្យភាគីវិវាទ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវកសាង និង បញ្ចូលឯកសារស៊ើបអង្កេតទៅក្នុងសំណុំរឿងវិវាទ។

មាត្រា ៩ ..

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវសម្រុះសម្រួលវិវាទក្រៅពីករណី ដែលមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យនេះ ។

ការសម្រុះសម្រួលត្រូវអនុវត្តតាមការណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

មាត្រា ១០ ..

បន្ទាប់ពីការស៊ើបអង្កេត ប្រសិនបើឃើញថា វិវាទមិនអាចត្រូវបានដោះស្រាយដោយសមធម៌នៅថ្នាក់ស្រុក ខណ្ឌ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំរឿងវិវាទទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង តាមការយល់ឃើញផ្ទាល់របស់ប្រធាន ឬតាមសំណើរបស់ភាគីវិវាទទាំងសងខាង ចំពោះករណីដូចតទៅ :

(១) ជនម្នាក់ទាមទារដីច្រើនក្បាល ដែលជាកម្មវត្ថុនៃការប្តឹងទាមទាររបស់ភាគីតូចតាចមួយចំនួនដែរ ។

(២) ភាគីម្ខាងនៃវិវាទ គឺជាអាជ្ញាធរមានឋានៈខ្ពស់ ។

(៣) ករណីមានវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ។

(៤) វិវាទដែលពាក់ព័ន្ធនឹងដីសាធារណៈរបស់រដ្ឋ ។

មាត្រា ១១ ..

ប្រសិនបើការដោះស្រាយអាចសំរេចបានដោយមានការព្រមព្រៀងជាឯកច្ឆន្ទពីភាគីវិវាទ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍ជូនគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ហើយត្រូវចំលងជូនការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌមួយច្បាប់ ដើម្បីចាប់ផ្តើមដំណើរការ

អនុវត្តនីតិវិធីនៃការចុះបញ្ជីក្បាលដីដែលបានដោះស្រាយរួច ។

ប្រសិនបើការដោះស្រាយមិនអាចសំរេចបាន គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវបញ្ជូនវិវាទ រួមជាមួយនឹងរបាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីការសម្រុះសម្រួលជូនគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង។

## ជំពូកទី ៥
## គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង

**មាត្រា ១២ ..**

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានសមាសភាពដូចខាងក្រោម :

- អភិបាល ឬ អភិបាលរងខេត្ត ក្រុង ជាប្រធាន
- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត ក្រុង ជាសមាជិក

ឈ្មោះប្រធាន និងសមាជិកនៃគណៈកម្មការសុរិយោដីនេះ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ប្រធានគណៈកម្មការសុរិយោដីខេត្ត ក្រុង អាចអញ្ជើញតំណាងស្រុក ខណ្ឌ ឃុំ សង្កាត់ ឬមន្ទីរជុំវិញខេត្ត ក្រុង ដែលពាក់ព័ន្ធឱ្យចូលរួមជាសមាជិកអាដហុក ។

**មាត្រា ១៣ ..**

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានភារកិច្ចសម្រុះសម្រួលវិវាទដូចមានចែងក្នុងមាត្រា ១០ និង មាត្រា ១១ វាក្យខ័ណ្ឌទី ២ នៃអនុក្រឹត្យនេះ ។

សមាជិកគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

**មាត្រា ១៤ ..**

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានលេខាធិការដ្ឋានមួយ ជាសេនាធិការ និងជាអង្គភាពស៊ើបអង្កេត ។

មន្ត្រីបំរើការងារនៅលេខាធិការដ្ឋាន ជាមន្ត្រីមុខងារសាធារណៈ ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមសំណើរបស់គណៈកម្មការសុរិយោដី ។

លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានមុខងារ ភារកិច្ចដូចតទៅ :

- ទទួលសំណុំរឿងវិវាទពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និង រាល់ពាក្យបណ្តឹងទាក់ទងនឹងវិវាទដីធ្លី
- ស៊ើបអង្កេតតាមការណែនាំរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង
- ធ្វើរបាយការណ៍ អំពីលទ្ធផលនៃការស៊ើបអង្កេត
- រៀបចំការប្រជុំរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង
- ធ្វើកំណត់ហេតុ អំពីដំណើរការសម្រុះសម្រួល និងធ្វើរបាយការណ៍អំពីលទ្ធផល នៃការសម្រុះសម្រួល
- បញ្ជូនកំណត់ហេតុ និងរបាយការណ៍ទាំងនេះ ទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ ក្នុងករណីការសម្រុះសម្រួលបានសំរេច ត្រូវផ្ញើលទ្ធផលនៃការសម្រុះសម្រួលទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ
- រៀបចំ និងតំកល់ទុកឯកសារ ។

## ជំពូកទី ៦
## ការសម្រុះសម្រួលនៅថ្នាក់ខេត្ត ក្រុង

### មាត្រា ១៥ ..

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ពុំមានសិទ្ធិសំរេចលើករណីវិវាទណាមួយទេ ប៉ុន្តែអាចបញ្ចប់វិវាទបាន ក្នុងករណីភាគីវិវាទទាំងអស់ព្រមព្រៀងគ្នាជាឯកច្ឆន្ទ ។

ក្នុងករណីដែលវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង សំណុំរឿងវិវាទនេះ ត្រូវបានបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

### មាត្រា ១៦ ..

ប្រសិនបើការសម្រុះសម្រួលអាចសំរេចបាន គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវផ្ញើលទ្ធផលជូនការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ដើម្បីចាប់ផ្តើមដំណើរការអនុវត្តនីតិវិធីនៃការចុះបញ្ជីក្បាលដី ដែលបានដោះស្រាយរួច ។

ប្រសិនបើការដោះស្រាយមិនអាចសំរេចបាន គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវបញ្ជូនសំណុំរឿងវិវាទ រួមជាមួយនឹងរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីការសម្រុះសម្រួល ជូនគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

## ជំពូកទី ៧
## គណៈកម្មការសុរិយោដីថ្នាក់ជាតិ

### មាត្រា ១៧ ..

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសមាសភាពដូចខាងក្រោម :

-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាប្រធាន

-រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ ជាសមាជិក

-រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

ឈ្មោះប្រធាន និងសមាជិកនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវតែងតាំងដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចអញ្ជើញក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ឱ្យមកចូលរួមជាសមាជិកអាដហុក ។

### មាត្រា ១៨ ..

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសមត្ថកិច្ចចេញសេចក្តីសំរេចលើវិវាទដីភោគៈ ដែលគណៈកម្មការសុរិយោដីថ្នាក់ក្រោម ឬគណៈកម្មការរដ្ឋបាលពុំអាចសម្រុះសម្រួលបានដូចមានចែងក្នុងមាត្រា ១៦ និងវិវាទដែលមានចែងក្នុងចំណុចទី ២ នៃមាត្រា ៣ នៃអនុក្រឹត្យនេះ។

សមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ។

### មាត្រា ១៩ ..

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានលេខាធិការដ្ឋានមួយ ជាសេនាធិការ និងជាអង្គភាពស៊ើបអង្កេត។

លេខាធិការដ្ឋាននេះ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់ ដែលត្រូវ

តែងតាំងដោយរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

មន្ត្រីបំរើការងារនៅលេខាធិការដ្ឋាន ជាមន្ត្រីមុខងារសាធារណៈ ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមសំណើរបស់គណៈកម្មការសុរិយោដី ។

លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ មានតួនាទីដូចតទៅ :

-ទទួលសំណុំរឿងវិវាទពីគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងរាល់ពាក្យបណ្តឹងទាក់ទងនឹងវិវាទដីធ្លី

-ស៊ើបអង្កេតតាមការណែនាំរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ

-ធ្វើរបាយការណ៍អំពីលទ្ធផលនៃការស៊ើបអង្កេត

-រៀបចំការប្រជុំរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ

-ធ្វើកំណត់ហេតុអំពីសវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ និងធ្វើរបាយការណ៍អំពីលទ្ធផលនៃការដោះស្រាយ

-បញ្ជូនកំណត់ហេតុ និងភស្តុតាងទាំងអស់ទៅតុលាការ នៅពេលមានការប្តឹងតវ៉ាលើសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិទៅតុលាការ

-រៀបចំ និងតំកល់ទុកឯកសារ ។

## ជំពូកទី ៨
## ការដោះស្រាយនៅថ្នាក់ជាតិ

**មាត្រា ២០ ..**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានយុត្តាធិការពេញលេញក្នុងការធ្វើសេចក្តីសំរេចទទួលស្គាល់ភោគី ឬកម្មសិទ្ធិករស្របច្បាប់ ។

ប្រសិនបើភាគីវិវាទ មិនយល់ព្រមតាមសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ភាគីវិវាទមានសិទ្ធិប្តឹងទៅតុលាការ ដូចមានចែងក្នុងមាត្រា ២៣ នៃអនុក្រឹត្យនេះ ។

**មាត្រា ២១ ..**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវពិនិត្យឡើងវិញនូវរាល់ឯកសារទាំងអស់ដែលទាក់ទងនឹងវិវាទ ហើយប្រសិនបើយល់ឃើញថាចាំបាច់ អាចបញ្ជាឱ្យមានការស៊ើបអង្កេតបន្ថែមទៀត ពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ និងរៀបចំបើកសវនាការមុនពេលធ្វើសេចក្តីសំរេចលើវិវាទ ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវពិនិត្យដើម្បីបើកសវនាការអំពីវិវាទ តាមការស្នើសុំរបស់ភាគីណាមួយ ។

ក្នុងករណីដែលគណៈកម្មការសុរិយោដីថ្នាក់ជាតិធ្វើការពិគ្រោះយោបល់ជាមួយភាគីណាមួយ នោះភាគីផ្សេងៗទៀត មានសិទ្ធិទទួលបានការជូនដំណឹងជាមុន អំពីការពិគ្រោះយោបល់នេះ ដើម្បីមានវត្តមាននៅក្នុងការពិគ្រោះយោបល់ ប្រសិនបើគណៈកម្មការសុរិយោដីថ្នាក់ជាតិយល់ឃើញថាចាំបាច់ ។

## មាត្រា ២២ ..

សេចក្តីសំរេចត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានសេចក្តីសង្ខេបអំពីករណីវិវាទ និងហេតុផលលំអិតនៃការធ្វើសេចក្តីសំរេច ។

## មាត្រា ២៣ ..

ភាគីវិវាទ មានសិទ្ធិស្នើឱ្យមានការពិនិត្យឡើងវិញផ្នែកច្បាប់ លើការសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ដោយប្តឹងទៅតុលាការក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ ចាប់ពីថ្ងៃទទួលបានសេចក្តីសំរេច ។

ប្រសិនបើតុលាការបញ្ជូនរឿងក្តីទៅគណៈកម្មការសុរិយោដីវិញ ដោយហេតុថាគណៈកម្មការសុរិយោដីមិនបានអនុវត្តតាមនីតិវិធីសមស្រប ឬដោយមានវិវាទអំពីផលប្រយោជន៍ ឬដោយមិនបានផ្តល់ហេតុផលសមរម្យ ឬដោយអនុវត្តហួសពីសមត្ថកិច្ចរបស់ខ្លួន នោះគណៈកម្មការសុរិយោដី ត្រូវចាត់វិធានការអនុវត្តតាមសំណូមពររបស់តុលាការ ។

ភាគីដែលស្នើសុំការពិនិត្យឡើងវិញផ្នែកច្បាប់ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីបណ្តឹង ទៅលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ លេខាធិការដ្ឋាន ត្រូវធានាការពារសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីចំពោះតុលាការ ។

តុលាការ ត្រូវធ្វើច្បាប់ចម្លងនៃសាលក្រម ឬសាលដីកា ដែលបានចូលជាស្ថាពរ មកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដើម្បីចាត់ចែងដំណើរការអនុវត្តនីតិវិធីនៃការចុះបញ្ជីដី ។

ប្រសិនបើគ្មានបណ្តឹងក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ ដូចបានកំណត់នៅក្នុងមាត្រានេះ នោះសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវចាត់ទុកជាស្ថាពរ ។

## ជំពូកទី ៩
## ការចុះបញ្ជី

**មាត្រា ២៤ ..**

បន្ទាប់ពីសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសុពលភាពអាចអនុវត្តបាន គណៈកម្ម-ការសុរិយោដីថ្នាក់ជាតិ ត្រូវផ្ញើសេចក្តីសំរេចនោះ ទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ដើម្បីចាត់ចែងធ្វើការចុះបញ្ជីក្បាលដីតាមនីតិវិធីដែលបានកំណត់ ។

## ជំពូកទី ១០
## បទប្បញ្ញត្តិរដ្ឋបាល

**មាត្រា ២៥ ..**

ប្រសិនបើសមាជិករបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានផលប្រយោជន៍នៅក្នុងវិវាទ សមាជិកនោះ ត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនេះ ហើយគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវតែងតាំងសមាជិកថ្មីជំនួសវិញ ។

ប្រសិនបើសមាជិករបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ឬ ថ្នាក់ជាតិ មានផលប្រយោជន៍នៅក្នុងវិវាទ សមាជិកនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនេះ ។ ប្រសិនបើចាំបាច់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចតែងតាំងសមាជិកថ្មីជំនួសវិញ ។

ក្នុងករណីដែលវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវតែងតាំងសមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិឱ្យធ្វើជាប្រធានអាដហុក ដើម្បីដោះស្រាយករណីវិវាទនេះ ។

**មាត្រា ២៦ ..**

ជនដែលត្រូវបានបញ្ជាក់ថាជាកម្មសិទ្ធិករ ឬភោគីស្របច្បាប់ នៃក្បាលដី ដែលមានវិវាទក្រោមនីតិវិធីដែលមានចែងក្នុងអនុក្រឹត្យនេះ ត្រូវបង់ថ្លៃសេវានៃការចុះបញ្ជីក្បាលដី អនុលោមតាមមាត្រា ២៣០ នៃច្បាប់ភូមិបាល ។

មាត្រា ២៧ ..

ភាគីវិវាទ ត្រូវបានជូនដំណឹងជាមុនក្នុងរយៈពេលមួយសមហេតុផល អំពីការប្រជុំដើម្បីសម្រុះសម្រួល ឬសំរេចលើវិវាទក្រោមអនុក្រឹត្យនេះ។

ភាគីវិវាទ មានសិទ្ធិចូលខ្លួនដោយខ្លួនឯង និងអាចរកជំនួយមនុស្ស ឬអង្គការណាមួយ ដើម្បីជួយខ្លួន ក្នុងពេលសម្រុះសម្រួលវិវាទនៅគ្រប់ថ្នាក់ ។

ភាគីវិវាទ មានសិទ្ធិចូលខ្លួនដោយខ្លួនឯង និងអាចរកជំនួយមនុស្ស ឬអង្គការណាមួយ ដើម្បីធ្វើជាតំណាងរបស់ខ្លួន ក្នុងពេលប្រជុំធ្វើសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដី ។

ភាគីវិវាទ មានសិទ្ធិបង្ហាញភស្តុតាងផ្ទាល់មាត់ ឬឯកសារជាក់ស្តែងដែលទាក់ទងនឹងវិវាទ ដែលត្រូវចាត់ទុកជាចំណែកមួយនៃឯកសារផ្លូវការនៃវិវាទ ។

ការប្រជុំរបស់គណៈកម្មការសុរិយោដីត្រូវធ្វើឡើងជាសាធារណៈ ។

គណៈកម្មការសុរិយោដី ត្រូវរក្សាឯកសារផ្លូវការនៃវិវាទនីមួយៗ ដែលរួមមានឯកសារទាំងអស់ និងភស្តុតាងជាក់ស្តែងផ្ទាល់មាត់ និងលាយលក្ខណ៍អក្សរ អំពីវិវាទ ។ ឯកសារផ្លូវការដែលទាក់ទងនឹងវិវាទ ត្រូវបានបើកឱ្យភាគីពាក់ព័ន្ធពិនិត្យ ។

សេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវអមដោយរបាយការណ៍ស្តីពីដំណើររឿង និងដំណើរការដោះស្រាយវិវាទ ដែលផ្អែកលើភស្តុតាងទាំងឡាយ ដែលអាចទុកចិត្តបាន និងត្រឹមត្រូវ ដែលជាផ្នែកនៃឯកសារផ្លូវការ ។

ច្បាប់ចម្លងនៃសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវផ្តល់ឱ្យភាគី វិវាទនីមួយៗ ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចេញប្រកាសណែនាំអនុវត្តអនុក្រឹត្យនេះ ។

មាត្រា ២៨ ..

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានសិទ្ធិប្រើប្រាស់ត្រារបស់ការិយាល័យរៀបចំដែនដី នគរូប-នីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្ត ក្រុង ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី ១១
## ប្រភពធនធាន

**មាត្រា ២៩ ..**

គណៈកម្មការសុរិយោដី មានខ្ទង់ថវិកាដោយឡែក ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា ៣០ ..**

ប្រភពធនធាន និងថវិកា របស់គណៈកម្មការសុរិយោដី ត្រូវបានផ្តល់ដោយ :

- ថវិកាជាតិ
- ហិរញ្ញប្បទានបានមកពីប្រទេសក្រៅ ឬអង្គការផ្តល់ជំនួយអន្តរជាតិ ។

## ជំពូកទី ១២
## អវសានប្បញ្ញត្តិ

**មាត្រា ៣១ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣២ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូប-នីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អភិបាលខេត្ត ក្រុងទាំងអស់ និងមន្ត្រី ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែ ឧសភា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យរបស់សម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត ក្រុង
- ដូចមាត្រា ៣២
- ឯកសារ កាលប្បវត្តិ